## កម្មវិធីថ្នាក់វិទ្យាល័យ (DP)

សាលាអន្តរជាតិក្រុងភ្នំពេញផ្តល់ជូននូវសមត្ថភាពយ៉ាងទូលំទូលាយនៅក្នុងថ្នាក់ទី១១ និងថ្នាក់ទី១២ តាមរយៈសញ្ញាប័ត្រទុតិយភូមិរបស់សាលាអន្តរជាតិក្រុងភ្នំពេញ រួមមានសញ្ញាប័ត្រទុតិយភូមិសាលាអន្តរជាតិក្រុងភ្នំពេញ បូករួមនឹងសញ្ញាប័ត្រ IB ។

### មាគ៌ាបីឆ្ពោះទៅរកភាពជោគជ័យ

សិស្សានុសិស្សមានឱកាសដើម្បីទទួលបាននូវសញ្ញាប័ត្រទុតិយភូមិនៅសាលាអន្តរជាតិក្រុងភ្នំពេញតាមរយៈប្រព័ន្ធក្រេឌីតជាឆមាស ។ ប្រព័ន្ធនេះគឺជាគុណភាពដែលទទួលស្គាល់ជាអន្តរជាតិមួយជាប្រយោជន៍ក្នុងការចូលរៀននៅមហាវិទ្យាល័យ ។

សិស្សានុសិស្សអាចទទួលបានសញ្ញាប័ត្រទុតិយភូមិរបស់សាលាអន្តរជាតិក្រុងភ្នំពេញ បូករួមនឹងសញ្ញាប័ត្រទុតិយភូមិ IB ទៅលើមុខវិជ្ជាដែលពួកគេពូកែ ។ សញ្ញាប័ត្រ IB អាចជាក្រេឌីតសំរាប់ចូលរៀននៅមហាវិទ្យាល័យ / សកលវិទ្យាល័យ ។

សញ្ញាប័ត្រទុតិយភូមិ IB ដែលប្រកបដោយកិត្យានុភាពត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាការត្រៀមលក្ខណៈដ៏ល្អបំផុតសំរាប់ថ្នាក់មហាវិទ្យាល័យ ។ សិស្សានុសិស្សដែលសំរេចបានជោគជ័យក្នុងកម្មវិធីសិក្សានេះជឿជាក់ថានឹងបានចូលរៀននៅមហាវិទ្យាល័យ / សកលវិទ្យាល័យដែលល្អបំផុត នៅលើពិភពលោក ។




"សាលាអន្តរជាតិក្រុងភ្នំពេញផ្តល់អំណាចដល់សិស្សក្នុងបរិយាកាសអន្តរជាតិប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ដើម្បីសំរេចអោយបាននូវសក្តានុពលភាពតាមរយៈឧត្តមភាពនៃការសិក្សា និងឧត្តមភាពនៃបុគ្គលម្នាក់ៗ និងដើម្បីបណ្តុះអោយក្លាយទៅជាពលរដ្ឋសាកលដែលបង្កើតនូវអ្វីៗផ្សេងៗប្រកបដោយភាពទទួលខុសត្រូវខ្ពស់"

សាលាអន្តរជាតិក្រុងភ្នំពេញជាសាលាដែលមិនរកប្រាក់ចំណេញ មិនបំរើសាសនាណាមួយ ជាសាលាពិភពលោកមានស្តង់ដា IB ដែលផ្តល់ជូននូវការអប់រំដែលទទួលស្គាល់ដោយអន្តរជាតិសំរាប់សិស្សកម្ពុជានិង



បរទេសដែលមានអាយុចាប់ពី៣ឆ្នាំដល់១៨ឆ្នាំ ។

ភាសាប្រើប្រាស់ក្នុងការបង្រៀនគឺភាសាអង់គ្លេសហើយសាលាយើងខ្ញុំ មានទីតាំងនៅចំកណ្តាលទីក្រុងភ្នំពេញដែលនៅជិតនឹងមជ្ឈមណ្ឌលពាណិជ្ជកម្ម ស្ថានទូត អង្គការក្រៅរដ្ឋាភិបាល និងទីប្រជុំជន ។ គ្រូបង្រៀនដែលប្រកបដោយទេពកោសល្យរបស់យើងប្តេជ្ញាធានាអោយបាននូវការអប់រំ ដ៏ល្អប្រសើរមួយដល់សិស្សានុសិស្ស និងកម្មវិធីបង្រៀនរបស់យើងផ្តល់ជូននូវកម្មវិធីសិក្សាស្តង់ដា IB មួយយ៉ាងពិតប្រាកដនៅក្នុងប្រទេសកម្ពុជា ។

សាលាអន្តរជាតិក្រុងភ្នំពេញមានកម្មវិធីសិក្សាជាច្រើន និងខុសប្លែកគ្នា ។ ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍ចំពោះព័ត៌មានបន្ថែមអំពីសហគមន៍អ្នកសិក្សារបស់យើងខ្ញុំ សូមចូលទៅកាន់គេហ៍ទំព័រ រឺទំនាក់ទំនងមកយើងខ្ញុំផ្ទាល់តាមរយៈព័ត៌មានខាងក្រោម ។



**ទំនាក់ទំនងលំអិត**
ប្រអប់សំបុត្រលេខ ១៣៨
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ:(០២៣) ២១៣ ១០៣
លេខហ្វាក់:(០២៣) ២១៣ ១០៤
អ៊ីម៉ែល: ispp@ispp.edu.kh
វិបសាយ: www.ispp.edu.kh

**ការិយាល័យកណ្តាល**
១៤៦ មហាវិថីព្រះនរោត្តម

**ការិយាល័យបឋមសិក្សា**
១៩១ មហាវិថីព្រះនរោត្តម

**ការិយាល័យមធ្យមសិក្សា**
១៥៨ មហាវិថីព្រះនរោត្តម

INTERNATIONAL SCHOOL OF PHNOM PENH

# THE INTERNATIONAL SCHOOL OF PHNOM PENH



## កម្មវិធីថ្នាក់បឋមសិក្សា (PYP)

សាលាបឋមសិក្សារបស់យើងខ្ញុំចាប់ទទួលសិស្សពីអាយុ ៣ឆ្នាំ ដល់ ១១ឆ្នាំ ហើយផ្តល់ជូននូវកម្មវិធីសិក្សាមួយដែលប្រមូលផ្តុំដោយការស្រាវជ្រាវ និងការអនុវត្តដ៏ល្អបំផុតពីប្រព័ន្ធជាតិ និង សាលាអន្តរជាតិជាច្រើន។ ចំនុចសំខាន់របស់កម្មវិធីនេះគឺជាការ ប្តេជ្ញាចិត្តចំពោះការរិះរកប្រកបដោយគោលបំនង និងរចនាសម្ព័ន្ធ ច្បាស់លាស់ដែលជាយាននាំមុខគេក្នុងការសិក្សារៀនសូត្រ។

សិស្សានុសិស្សបានផ្សារភ្ជាប់យ៉ាងសកម្មក្នុងការរៀនសូត្រអំពីបញ្ហា និង ប្រធានបទទាំងឡាយដែលមានសារៈសំខាន់ជាសកល។ ទាំងនេះត្រូវបានរចនាឡើងដើម្បីបង្ហាញសិស្ស ដែលឆ្លុះបញ្ចាំងពីបុគ្គលិកលក្ខណៈជាអ្នកសិក្សារៀនសូត្រនិងការសិក្សាទាំងអស់នេះហើយដែលអាចអោយពួកគេចូលរួមក្នុងពិភពលោកបាន យ៉ាងងាយស្រួលពេលពួកគេពេញវ័យ។ ថ្នាក់រៀននៅបឋមសិក្សាគឺជា ការសិក្សាបែបសិស្សមជ្ឈមណ្ឌល ដែលសិស្សានុសិស្សទាំងអស់ត្រូវបានលើកទឹកចិត្តហើយ និងអភិវឌ្ឍខ្លួនអោយក្លាយទៅជាអ្នកសិក្សាដ៏សកម្ម និងអ្នកត្រិះរិះពិចារណាដ៏ល្អិតល្អន់។ សិស្សានុសិស្សក៏រៀនអំពីទំនួលខុសត្រូវផ្នែកសង្គមផងដែរ។

សិស្សានុសិស្សបង្កើនចំណេះដឹងតាមរយៈការសិក្សាស្រាវជ្រាវទៅ







លើប្រធានបទចំនួន៦ ដែលមានសារៈសំខាន់ជាសកលពោលគឺផ្តល់ និងធ្វើអោយមានតុល្យភាពដោយមុខវិជ្ជាចំនួន៦: ភាសា ការសិក្សាសង្គម គណិតវិទ្យា សិល្បៈ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ការអប់រំខ្លួន សង្គម និងការអប់រំកាយ។ សិស្សានុសិស្ស ក៏រៀនផ្នែកជំនាញឯកទេសផ្សេងៗផងដែរដូចជាកុំព្យូទ័រ ភាសាបរទេស ភាសាកំណើត ការអប់រំកាយ ការហែលទឹក បណ្ណាល័យ តន្ត្រី និង សិល្បៈ។ លើសពីនេះទៅទៀត យើងមានកម្មវិធីសិក្សាក្រៅម៉ោងជាច្រើន។

សំណុំឯកសារអ្នកសិក្សា ផ្តល់នូវទស្សនៈវិស័យយូរអង្វែងមួយ ស្តីពីការអប់រំដែលជាចំណងទាក់ទងគ្នានៃបណ្តុំកម្មវិធី IB ទាំងបី។ វាគឺជា



បណ្តុំនៃគំនិតដែលអាច បំផុស ជំរុញ និង ផ្តោតទៅលើការងារសាលា និងគ្រូបង្រៀនដោយបង្រួបបង្រួមអោយស្ថិតក្នុងគោលបំនងរួមតែមួយ។

សិស្សានុសិស្សសាលាអន្តរជាតិក្រុងភ្នំពេញត្រូវបានផ្តល់ជូននូវឱកាសដើម្បីបង្កើតនូវតម្លៃនៃសំណុំឯកសារអ្នកសិក្សាដូចខាងក្រោម:

| | |
|---|---|
| អ្នកសាកសួរ | អ្នកគិត |
| អ្នកទំនាក់ទំនង | អ្នកប្រថុយប្រថាន |
| ការយកចិត្តទុកដាក់ | ដែលពោរពេញដោយចំណេះដឹង |
| ដែលប្រកបដោយសីលធមិ | ដែលចេះថ្លឹងថ្លែងពិចារណា |
| មានចិត្តទូលាយ | ដែលចេះគិតល្អិតល្អន់ |

## កម្មវិធីថ្នាក់អនុវិទ្យាល័យ (MYP)

ថ្នាក់ទី៦-១០សិក្សាតាមកម្មវិធីថ្នាក់អនុវិទ្យាល័យក៏រិតបាក់ឌុបអន្តរជាតិ (MYP)។ វាជាកម្មវិធីអប់រំលក្ខណៈអន្តរជាតិមួយដែលបានរៀបចំឡើងជួយសិស្សក្នុងការអភិវឌ្ឍចំណេះដឹង ការយល់ដឹងឥរិយាបថ និង ជំនាញចាំបាច់សំរាប់ចូលរួមយ៉ាងសកម្ម និងប្រកបដោយទំនួលខុសត្រូវខ្ពស់ក្នុងពិភពលោកដែលកំពុងផ្លាស់ប្តូរដោយឥតឈប់ឈរ។

កម្មវិធីនេះជំរុញ និងគាំទ្រការអភិវឌ្ឍផ្នែកបញ្ញា និងស្មារតីរបស់សិស្សអនុវិទ្យាល័យ។ ការរៀនពីរបៀបរៀន និងរបៀបវាយតំលៃព័ត៌មានយ៉ាងល្អិតល្អន់គឺមានសារៈសំខាន់ដូចជាការសិក្សាជាក់ស្តែង។ មានមុខវិជ្ជាប្រកបដោយតុល្យភាពល្អជាច្រើនជាភាសាអង់គ្លេស ដូចជា ភាសា មនុស្សវិទ្យា វិទ្យាសាស្ត្រ គណិតវិទ្យា សិល្បៈ បច្ចេកវិទ្យា និងការអប់រំកាយ។

កម្មវិធីថ្នាក់អនុវិទ្យាល័យកំពុងតែពង្រីកទូទាំងសកលលោក និងត្រូវបានទទួលស្គាល់នៅក្នុងប្រទេសជាច្រើន។ សិស្សអាចផ្ទេរយ៉ាងងាយស្រួលរវាងសាលាអន្តរជាតិនៅក្រៅស្រុក និងក្នុងតំបន់ហើយអត្ថប្រយោជន៍បានមកពីកម្មវិធីនេះរួមមានការវិនិច្ឆ័យល្អិតល្អន់ និងស្តង់ដានៃការសិក្សាម៉ត់ចត់។ កម្មវិធីនេះធ្វើអោយសាលាអន្តរជាតិក្រុងភ្នំពេញក្លាយជាជំរើសដ៏ប្រសើរបំផុតសំរាប់សិស្សទាំងឡាយណាដែលនឹងបន្តរៀនយកសញ្ញាប័ត្រ IB ព្រមទាំងសិស្សទាំងឡាយណាដែលនឹងផ្លាស់ទៅសិក្សានៅសាលាអន្តរជាតិដ៏ទៃទៀត រឺក៏ត្រលប់ទៅប្រទេសកំណើតរបស់ខ្លួនវិញ។

កម្មវិធីថ្នាក់អនុវិទ្យាល័យមានទស្សនវិស័យជាសកលមួយ និងសង្កត់ធ្ងន់ទៅលើការយល់ដឹងពីវប្បធមិជំនាញនិងដំណើរការ និងទំនាក់ទំនងរវាងវិស័យចំណេះដឹង។ សិស្សានុសិស្សរបស់យើងចូលរួមយ៉ាងសកម្មក្នុងការងារសង្គមកីឡា និងសកម្មភាពវប្បធមិ ហើយនិងការផ្លាស់ប្តូរបទពិសោធន៍រវាងសាលានិងសាលា។ កម្មវិធីសិក្សាថ្នាក់វិទ្យាល័យនៅសាលាអន្តរជាតិក្រុងភ្នំពេញគឺជាស្ពានចំលងដែលមានការថែទាំយ៉ាងប្រសើររវាងការអប់រំនៅបឋមសិក្សា និងនៅវិទ្យាល័យ។

